**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខៈ ១៣១
ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០០៣
សាលដីកា
លេខៈ ២២៥
ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០០៣

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០០៣ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ............ ជាប្រធាន
២-លោក ............... ជាចៅក្រម
៣-លោក ............... ជាចៅក្រម
៤-លោក ............... ជាចៅក្រម
៥-លោក ............... ជាចៅក្រម

**ក្រឡាបញ្ជី**

-កញ្ញា ...............

**តំណាងមហាអយ្យការ**

-លោក **ឈួន ចាន់ថា** ជាព្រះរាជអាជ្ញា

**ចៅក្រមរបាយការណ៍**

លោក ................. (អវត្តមាន)

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ ១៤២(ឈ) ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ១២៨ ចុះថ្ងៃទី២៨ ខែកុម្ភៈឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍រាជធានីៈ

ដើមចោទឈ្មោះ ឡុទ (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ ៤៩ ឆ្នាំ ជាតិខ្មែរ មុខរបរប្រធានក្រុមហ៊ុនអ៊ុយទៀង ទីលំនៅសព្វថ្ងៃទីផ្ទះលេខ ៣៨០Eo ផ្លូវលេខ ១៩៣ សង្កាត់អូរឡាំពិក ខណ្ឌចំការមន ក្រុងភ្នំពេញ ។

មានមេធាវីលោក .......... ។

ចុងចម្លើយឈ្មោះ ចសជ (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤៦ ឆ្នាំ ជាតិខ្មែរមុខរបរប្រធានក្រុមហ៊ុន ថៃហេងចាន់ ទីលំនៅសព្វថ្ងៃទីផ្ទះលេខ ៦៤ ផ្លូវលេខ ១២៨ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

មានមេធាវីលោក ............... ។

**កម្មវត្ថុបណ្តឹងៈ** -ប្តឹងទាមទារប្រាក់ចំនួន ១២៣.៧៤៥,៨៣$
-ប្រាក់ពិន័យ ៥០០០០ដុល្លា

-មោឃៈភាពកិច្ចសន្យាលក់ ទិញផ្ទះនិងដីឡូត៍ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០០ កិច្ចសន្យាពន្យាពេលសងប្រាក់ និងការប្រាក់ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០០ និងកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០០ ទាមទារជម្ងឺចិត្ត ១០០០០ដុល្លា

-***បណ្ដឹងតប:*** ប្ដឹងទាមទារប្រាក់ជំពាក់ថ្លៃស្រាបៀរចំនួន ៦០០០០ដុល្លា និងប្រាក់ខ្ចី ៥០០០០ ដុល្លា ។

បានឃើញបណ្ដឹងសាទុក្ខលេខ ៣៤៧ ចុះថ្ងៃទី២០ ខែកញ្ញាឆ្នាំ២០០២ របស់លោក......... មេធាវីតំណាងឲ្យឈ្មោះ ឡុទ ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៤២ (ឈ) ចុះថ្ងៃទី ០៥ ខែកញ្ញាឆ្នាំ ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៣១ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ របស់តុលាការកំពូល។

តាមពាក្យបណ្ដឹងចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០០ ចុះថ្ងៃទី១៧ ខែវិច្ឆកា ឆ្នាំ២០០០ និងចុះថ្ងៃទី២៣ ខែវិច្ឆកា ឆ្នាំ២០០០ របស់ដើមចោទឈ្មោះ ឡុទ ថា: ខ្លួនប្ដឹងទាមទារប្រាក់ចំនួន ១២៣.៧៤៥,៨៣ដុល្លា និងប្រាក់ផាកពិន័យចំនួន ៥០០០០ដុល្លា ព្រមទាំងសុំមោឃៈភាពកិច្ចសន្យាលក់ ទិញផ្ទះនិងដី កិច្ចសន្យាពន្យាពេលសងប្រាក់ និងការប្រាក់និងកិច្ចសន្យាខ្ចីប្រាក់ព្រមទាំងសុំប្ដឹងទាមទារជម្ងឺចិត្ត ១០០០០ដុល្លា ។ ដោយសំអាងហេតុថា:ឈ្មោះ ចសធ ពុំបានគោរពទៅតាមកិច្ចសន្យាលក់ ទិញស្រាបៀរ ALAIN DELON ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៩ ។ឈ្មោះចសធ នាំចូលស្រាបៀរ ALAIN DELON ប្រភេទដបដែលសុទ្ធតែខូចគុណភាព ធ្វើឲ្យប៉ះពាល់ដល់សុខភាពអតិថិជន និងបាត់បង់ការគាំទ្រស្រាបៀរ ALAIN DELON ដែលក្រុមហ៊ុនអ៊ុយទៀង (ឡុទ) ខ្លួនទទួលខុសត្រូវផ្ដាច់មុខនៅក្នុងប្រទេសកម្ពុជា ធ្វើឲ្យខូចកេរ្ដិ៍ឈ្មោះ ធ្វើឲ្យខូចកិត្តិយសខ្លួន បាត់បង់អាជីវកម្មមិនអាចដំណើរការតទៅទៀតបាន ។ ស្ថិតក្នុងកិច្ចសន្យា ដែលខ្លួនបានអនុវត្តធ្វើជាមួយឈ្មោះ ចសធ នេះបានខាតបង់ប្រាក់ចំណាយរបស់ខ្លួនយ៉ាងធ្ងន់ធ្ងរទៅលើប្រាក់បៀវត្សន៍បុគ្គលិកចំនួនសរុបចំនួន ៧២.៥៧៣,៦៣ ដុល្លា ផ្សព្វផ្សាយពាណិជកម្មចំនួន ៥១.១៧៥,២០ដុល្លា សរុបចំនួន ១២៣.៧៤៥,៨៣ដុល្លា ។រីឯកិច្ចសន្យាលក់ ទិញផ្ទះនិងដីកិច្ចសន្យាពន្យាពេលសងប្រាក់ កិច្ចសន្យាខ្ចីប្រាក់ គឺឈ្មោះ ចសធ បាននិយាយតម្រូវឲ្យខ្លួនធ្វើជារូបភាពក្លែងបន្លំភ្នែកថៅកែចិនដែលឈ្មោះ ចសធ បានទាក់ទងនាំចូលស្រាបៀរ ALAIN DELON តែប៉ុណ្ណោះ តាមពិតអចលនទ្រព្យខ្លួន គឺបានដាក់បញ្ចាំធនាគារតាំងពីមុនកិច្ចសន្យាលក់ ទិញ ស្រាបៀរ ALAIN DELON នេះម្ល៉េះ ហេតុនេះហើយខ្លួនសុំប្ដឹងមោឃៈភាពកិច្ចសន្យាខាងលើទាំងអស់ ។

តាមពាក្យបណ្ដឹងតប ចុះថ្ងៃទី១២ ខែវិច្ឆកា ឆ្នាំ២០០០ របស់ចុងចម្លើយឈ្មោះ ចសធ ថា: ខ្លួនប្ដឹងទាមទារប្រាក់ជំពាក់ថ្លៃស្រាបៀរចំនួន ៦០០០០ដុល្លា និងប្រាក់ខ្ចីចំនួន ៥០០០០ដុល្លា ពីក្រុមហ៊ុនអ៊ុយទៀងតំណាងដោយឈ្មោះ ឡុទ និងនាងង៉ោ មុយ ។ ដោយហេតុថា កន្លងមក្រុមហ៊ុននាំចូលស្រាបៀរ ALAIN DELON នាំចូលស្រាបៀរមកបន្តបន្ទាប់មិនដែលមានការរាំងស្ទះ ដូចក្រុមហ៊ុនអ៊ុយ

ទៀង ចោទប្រកាន់នោះឡើយ ។ ដូចជាការដាក់ស្តែង ការនាំចូលត្រូវក្រុមហ៊ុនអ៊ុយទៀង ធ្វើលិខិតកុំម៉ង់នាំចូលជាផ្លូវការ ហើយមានទឹកប្រាក់ធានាពីធានាគារ ទើបក្រុមហ៊ុនអាចធ្វើការនាំចូលបានតាមកិច្ចសន្យាប្រការទី៤ និងដាក់ស្តែងឈ្មោះ ឡុទបាននៅជំពាក់ប្រាក់ក្រុមហ៊ុនរបស់ខ្លួនចំនួន ១១៣.០០០ដុល្លា មិនទាន់សងឲ្យក្រុមហ៊ុនខ្លួនតាំងពីខែមករា ឆ្នាំ២០០០ ។ ម្យ៉ាងទៀត ការលក់ដូររបស់ក្រុមហ៊ុនអ៊ុយទៀងក៏មិនដែលគោរពតាមផែនការដែរ គឺលក់តម្លើងថ្លៃក្នុងកម្លៃកំណត់ទីផ្សារ ហើយក្រុមហ៊ុនអ៊ុយទៀងនេះ តែងតែមកទាមទារឲ្យក្រុមហ៊ុនខ្លួនបញ្ចុះតម្លៃថ្លៃប្រាក់ដើមនាំចូលទៀតផង ។តម្លៃប្រាក់ដើមស្រាបៀរ ALAIN DELON កំប៉ុងចំណុះ ៣៥៥ML ក្នុងមួយកេសក្រុមហ៊ុនខ្លួនលក់ឲ្យក្រុមហ៊ុនអ៊ុយទៀង គឺតម្លៃ៩ដុល្លា ក្នុងមួយកេស ដោយក្នុងតម្លៃនេះក្រុមហ៊ុនខ្លួនបានកាត់ចេញ ២ ដុល្លា សម្រាប់ក្រុមហ៊ុនអ៊ុយទៀង ធ្វើការផ្សព្វផ្សាយពាណិជ្ជកម្ម ហើយក្រុមហ៊ុនអ៊ុយទៀង តែងតែកេងប្រវ័ញ្ចលើ តម្លៃផ្សាយពាណិជ្ជកម្មដែលក្រុមហ៊ុនផ្សាយពាណិជ្ជកម្មកំណត់ឲ្យទៀត ដូច្នេះ ប័ណ្ណបញ្ជាទិញរបស់ក្រុមហ៊ុនអ៊ុយទៀង គឺប្រភេទស្រាបៀរ ALAIN DELON កំប៉ុងចំណុះ ៣៥៥ML គឺស្រាបៀរមានគុណភាពល្អមិនដែលមានអតិថិជនណាម្នាក់ចោទប្រកាន់ម្តងណាឡើយ ។ចំពោះក្រុមហ៊ុនអ៊ុយទៀង បានចោទប្រកាន់ថាៈ ស្រាបៀរ ALAIN DELON ប្រភេទបដ ដែលខូចគុណភាពនោះ គឺជាស្រាបៀរទើបតែនាំចូលកាលពីខែកញ្ញា ឆ្នាំ២០០០ ហើយឈ្មោះឡុទគ្មានប្រាក់ទៅបង់ពន្ធនាំចូលតាមកិច្ចសន្យាលក់ ទិញ ស្រាបៀរក្រុមហ៊ុនខ្លួនធ្វើការបង់ពន្ធដោយខ្លួនឯង ហើយគ្រប់គ្រងដោយខ្លួនឯងចំណុចនេះ តាមកិច្ចសន្យាប្រការទី០៣ ហើយក្រុមហ៊ុនអ៊ុយទៀង សុខចិត្តទូទាត់ប្រាក់តាមចំនួនស្រាបៀរដឹកចេញពីឃ្លាំងដាក់ស្តែងក្រុមហ៊ុនអ៊ុយទៀង បានដឹកចេញ ៥០០កេស ទៅលក់ទីផ្សារអស់ហើយ ហេតុអ្វីបានទើបនិយាយថាស្រាបៀរខូចគុណភាព បើសិនជាខូចមែនហេតុអ្វីបានជាមានហាងជាច្រើនមករកទិញទៀត ។ លុះដល់ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០០ ស្រាប់តែមានដីកាឃាត់ទុកស្រាបៀររបស់ក្រុមហ៊ុនខ្លួន ធ្វើឲ្យមានការភ្ញាក់ផ្អើលតាមទីផ្សារ និងធ្វើឲ្យខូចកិត្តិយសដល់ក្រុមហ៊ុនខ្លួនយ៉ាងខ្លាំងក្រោយពីក្រុមហ៊ុនខ្លួនចុះស្រាវជ្រាវតាមហាងស៊ុប និងកន្លែងលក់ស្រាបៀរ ALAIN DELON មានអតិថិជនជាច្រើនពោលពាក្យថា ស្រាបៀរដឹកនាំមកនោះបានលក់អស់ហើយ ឈ្មោះឡុទ មិនបានដឹកស្រាបៀរទៅតាមហាងរបស់ពួកគេអស់ជាច្រើនអាទិត្យហើយ ។ ក្រុមហ៊ុនអ៊ុយទៀងមានចេតនាផ្អាកដឹកស្រាបៀរចូលតាមហាង ហើយមួលបង្កាច់ថា ស្រាបៀរខូចគុណភាប គឺជាលេសមួយមិនព្រមសងប្រាក់ថ្លៃស្រាបៀរប្រភេទកំប៉ុងដែលក្រុមហ៊ុនខ្លួនបានផ្គត់ផ្គង់តាំងពីខែមករា ឆ្នាំ២០០០ មានទឹកប្រាក់ចំនួន១១៣.០០០ដុល្លាឲ្យក្រុមហ៊ុនខ្លួន ។ខ្លួនសូមបញ្ជាក់ថាៈ ស្រាបៀរខូចគុណភាព លុះត្រាតែមានរសជាតិជូរផ្អូមឬហួសកំណត់ផលិត ហើយប្រសិនបើក្រុមហ៊ុនអ៊ុយទៀងមានចេតនា េឲ្យស្រាបៀរនោះខូចគុណភាពនោះ គឺងាយស្រួលណាស់ គ្រាន់តែយកស្រាបៀរនោះទៅក្លាសសេរួចហើយ យកទៅហាលថ្ងៃនោះស្រាបៀរនឹងខូចគុណភាពភ្លាម ទោះជាស្រាបៀរម៉ាកអ្វីក៏ខូចដែរចំពោះស្រាបៀរដបចំណុះ ៦៤០ML នេះមិនស្ថិតក្នុងប័ណ្ណបញ្ជាទិញរបស់ក្រុមហ៊ុនអ៊ុយទៀងទេ ។

**ខ្លួនសំណូមពរៈ**

១-សុំបដិសេធដីកាចារលើពាក្យសុំរបស់ឈ្មោះ ឡុទ ដែលប្តឹងសុំឃាត់ទុកនូវស្រាបៀរស្តុកទុកនៅក្នុងឃ្លាំងលេខ ១៥ ផ្លូវលេខ ១៦៣ សង្កាត់អូរឡាំពិក ខណ្ឌចំកាមន ក្រុងភ្នំពេញ ។

២-ឲ្យឈ្មោះ ឡុទ និងនាង ង៉ោ មុយ សងប្រាក់ថ្លៃជំពាក់ស្រាបៀរកំប៉ុងដែលនាំចូលកាលពីខែមករា ឆ្នាំ២០០០ ចំនួន ១១៣.០០០ដុល្លាសងឲ្យក្រុមហ៊ុនខ្លួន ។

៣-ទាមទារសងជំងឺចិត្ត ការប្រាក់ការខូចខាតពេលវេលារកស៊ី ការខាតបង់កិត្តិយសក្រុមហ៊ុន ការចំណាយផ្សេងៗសរុប ៨០០០០ដុល្លា ។

៤-សុំរក្សានូកិច្ចសន្យាលក់ ទិញស្រាបៀរ ALAIN DELON ប្រភេទកំប៉ុង ចំណុះ៣៥៥ML ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៩ គ្រប់ចំនួន ២៥០.០០០កេស ដោយមិនអាចរំលាយបាន និងឲ្យស្របតាមច្បាប់នៃកិច្ចសន្យារបស់ព្រះរាជាណាចក្រកម្ពុជា ។

តាមពាក្យបណ្តឹងបន្ថែមចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០០១ របស់មេធាវី.............. តំណាងឲ្យឈ្មោះ ចសធ ថាៈ សំណើសុំប្តឹងទាមទារប្រាក់ចំនួន ៤៥០.០០០ដុល្លា ពីការរំលោភលើកិច្ចសន្យាចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការលក់ ទិញ ស្រារបៀរ ALAIN DELON ចំនួន ២៥០០០០កេស ក្នុងរយៈ ពេល៣ឆ្នាំ ទាមទារប្រាក់ចំនួន ៣០.៦២៥ដុល្លា ពីការឃាត់ស្រាបៀរ ALAIN DELON ចំនួន១៧៥០កេស ដែលធ្វើឲ្យខូចខាតគុណភាព និងទាមទារប្រាក់ចំនួន ២.០០០.០០០ដុល្លា ពីការធ្វើឲ្យបាត់ទីផ្សារស្រាបៀរ ALAIN DELON ក្នុងព្រះរាជាណាចក្រកម្ពុជា ពីក្រុមហ៊ុន អ៊ុយទៀង បន្ថែមលើពាក្យបណ្តឹងតបចុះថ្ងៃទី០១/០២ ខែវិច្ឆកា ឆ្នាំ២០០០ របស់អ្នកស្រី ចសធ ។ ដោយហេតុថា យោងតាមកិច្ចសន្យាលក់ ទិញ ស្រាបៀរ ALAIN DELON ដែលធ្វើឡើងរវាងអ្នកស្រី ចសធ និងក្រុមហ៊ុនអ៊ុយទៀង ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៩ ក្រុមហ៊ុនអ៊ុយទៀង បានរំលោភលើកិច្ចសន្យាត្រង់ប្រការ៤ ដែលចែងថាៈ(នៅពេលភាគី"ខ")កុម៉ង់ទិញទំនិញក្នុងលើកនីមួយៗ ភាគី"ខ" ត្រូវធ្វើ Bank Guarantee ចំនួន១០០% នៃតម្លៃទំនិញសរុបឲ្យភាគី ក Bank Guarantee អាចបើសាច់ប្រាក់ដោយស្វ័យប្រវត្តិនៅពេលទំនិញដល់កំពង់ផែក្រុងព្រះសីហនុ និងប្រការ១៣ បានចែងអំពីការកុំម៉ង់ទិញទំនិញក្នុងរយៈពេល៣ឆ្នាំ គឺឆ្នាំទី១ ចំនួន ៥០០០០ កេស ឆ្នាំទី២ ចំនួន ១០០០០០កេស និងឆ្នាំទី៣ ចំនួន ១០០០០០កេស ភាគី ខ គឺក្រុមហ៊ុនអ៊ុយទៀងបានរំលោភលើប្រការ៤នេះ ដោយមិនបានធ្វើ Bank Guarantee ចំនួន១០០% នៃតម្លៃទំនិញសរុបសម្រាប់ឲ្យភាគី ក នៅពេលទំនិញមកដល់ផែក្រុងព្រះសីហនុឡើយ ។

ជាក់ស្តែងក្រុមហ៊ុនអ៊ុយទៀង នៅពេលជំពាក់លុយចំនួន ៦០០០០ដុល្លា ថ្លៃស្រាបៀរ ALAIN DELON ដែលខ្លួន(ក្រុមហ៊ុនអ៊ុយទៀង) យកទៅលក់អស់ហើយ ។ ចំណែកប្រការ១៣ នៃកិច្ចសន្យាចែងថា (ប្រសិនភាគីខ កុំម៉ង់ទំនិញក្នុងរយៈពេល៣ឆ្នាំ មិនបានគ្រប់ចំនួន ២៥០០០០កេសទេ ត្រូវបង់ប្រាក់ផាកពិន័យឲ្យភាគី ក ចំនួន៥០០០០ដុល្លា នៃឆ្នាំទី១ ក្នុងចំនួន ៥០០០០កេស ចំពោះឆ្នាំទី

២ និងទី៣ បើភាគី ខ កុម៉ង់ទិញស្រាបៀរមិនបានគ្រប់ចំនួន ២០០០០០កេសទេនោះ ក៏ត្រូវផាកពិន័យក្នុងមួយកេសចំនួន ២ដុល្លា ឲ្យភាគី ក វិញ ។

ភាគីក្រុមហ៊ុនអ៊ុយទៀង បានរំលោភលើប្រការ១៣ នៃកិច្ចសន្យានេះ ព្រោះរយៈកាលកន្លងមក ភាគីនេះបញ្ជាទិញស្រាបៀរបានតែ ៣០០០០ កេស ។ ដោយសារតែក្រុមហ៊ុននេះ(ក្រុមហ៊ុនអ៊ុយទៀង) កុម៉ង់ទិញស្រាបៀរហើយមិនធ្វើ Bank Guarantee ដូចដែលកិច្ចសន្យាចែងក្នុងប្រការ៤ ទើបបណ្តាលឲ្យក្រុមហ៊ុនអ៊ុយទៀងជំពាក់ថ្លៃស្រាបៀរដែលក្រុមហ៊ុនថៃហេងចាន់ បាននាំចូលមកលក់ឲ្យក្រុមហ៊ុនអ៊ុយទៀងដល់ទៅ ៦០០០០ដុល្លា ។ ក្រុមហ៊ុនថៃហេចាន់ ឃើញដូច្នេះក៏សម្រេចមិនប្រគល់ទំនិញទាំង Container ឲ្យក្រុមហ៊ុនអ៊ុយទៀងទេ ដោយក្រុមហ៊ុននេះដឹកចេញពីឃ្លាំងស្តុកទុកប៉ុន្មានកេស ត្រូវទូទាត់លុយប៉ុណ្ណឹងកេសសិន ហើយម្យ៉ាងទៀតដោយរង់ចាំឲ្យភាគីអ៊ុយទៀង សងលុយជំពាក់ថ្លៃស្រាបៀរដែលខ្លួនបានលក់ឲ្យសិន ។ តែផ្ទុយទៅវិញក្រុមហ៊ុនអ៊ុយទៀង បែរជាទៅប្តឹងសុំឃាត់ស្រាបៀរចំនួន ១៨៨០កេស ដែលស្តុកទុកឃ្លាំងបណ្តាលឲ្យរាំងស្ទះដល់ការអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យា និងធ្វើឲ្យខូចខាតស្រាបៀរអស់ចំនួន ១៧៥០កេស ។មិនតែប៉ុណ្ណោះនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០០១ និងថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០១ ភាគីឡុទ បានធ្វើការចុះផ្សាយទៅតាមសារពត៌មានដែលបានបន្ទុះបង្អាប់អំពីគុណភាពស្រាបៀរ ALAIN DELON ធ្វើឲ្យបាត់នូវទីផ្សារស្រាបៀរ ALAIN DELON នៅកម្ពុជា ។

ខ្លួនតំណាងឲ្យអ្នកស្រីចសធ សុំប្តឹងទាមទារប្រាក់ពីក្រុមហ៊ុនអ៊ុយទៀង ទាំងអស់គឺ ២.៤៨០.៦២៥ ដុល្លា សំណងការខូចខាតក្នុងការប្តឹងផ្តល់ចំនួន ១០០.០០០ ដុល្លា និងសំណងជម្ងឺចិត្តចំនួន ៥០.០០០ដុល្លា បន្ថែមទៀត ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៤(៣) ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០០ ចុះថ្ងៃទី១៧ខែវិច្ឆកា ឆ្នា២០០០ និងចុះថ្ងៃទី២៣ ខែវិច្ឆកា ឆ្នាំ២០០០ របស់ឈ្មោះ ឡុទ ជាដើមចោទ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងតប ចុះថ្ងៃទី១២ ខែវិច្ឆកា ឆ្នាំ២០០០ របស់ឈ្មោះ ចសធ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ខ្លះៗ ។

៣-ទទួលស្គាល់លោកមេធាវី .......... តាមលិខិតចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០១ ការពារក្តីឲ្យលោក ឡុទ ជាដើមចោទ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៤-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិរបស់ឈ្មោះ ចសធ មកឲ្យឈ្មោះ គង់ ហេងលី ចុះថ្ងៃទី០៥ ខែវិច្ឆកា ឆ្នាំ២០០០ និងលិខិតសុំចំណាយក្តី លិខិតផ្ទេរសិទ្ធិពីឈ្មោះ ចសធ មកឲ្យលោកមេធាវី .............. ជាតំណាងចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០១ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៥-បង្គាប់ឲ្យឈ្មោះឡូទ សងប្រាក់ទៅឈ្មោះ ចសធ ចំនួន ៧៨.២៥០ដុល្លា (ប្រាំពីរម៉ឺនប្រាំបីពាន់ពីររយហាសិបដុល្លាអាមេរិក) ជាប្រាក់បំណុលចាប់តាំងពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ ។

៦-បង្គាប់ឲ្យឈ្មោះចសធ សងប្រាក់ទៅឲ្យឈ្មោះ ឡូទ ចំនួន ១២៣.៧៤៥,៨៣ដុល្លា ប្រាក់ពិន័យចំនួន ៥០០០០ដុល្លា និងប្រាក់ជម្ងឺចិត្តចំនួន ៨០០០០ដុល្លា ចាប់តាំងពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពរ ។

ក្នុងករណីឈ្មោះ ចសធ គ្មានប្រាក់សង សម្រេចរឹបអូសទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ឈ្មោះនេះលក់ឡាយឡុងទូទាត់សំណង ។បើនៅមានជាប់បំណុលទៀត ហើយជននេះមានចេតនារឹងទទឹងសម្រេចចាប់ដាក់គុកបង្ខំរូបកាយលើឈ្មោះ ចសធតាមច្បាប់ ។

៧-មោឃភាពកិច្ចសន្យាលក់ ទិញផ្ទះ និងដីឡូត៍ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០០ កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០០ និងកិច្ចសន្យាស្តីពីការពន្យាពេលសងប្រាក់ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០០ ជាអសារបង់តាមមាត្រាទី១០ នៃក្រឹត្យច្បាប់លេខ ៣៨ក្រច ចុះថ្ងៃទី២៨ខែតុលា ឆ្នាំ១៩៨៨ ចាប់តាំងពីថ្ងៃប្រកាស់សាលក្រមនេះតទៅ ។

៨-បង្គាប់ឲ្យឈ្មោះ ចសធ តាមរយៈលោក គង់ ហេងលី និងលោកមេធាវីតំណាង..............បង់ប្រាក់ប្រដាប់ក្តី គឺបង់ពន្ធបញ្ជីក្តី និងពន្ធហ្នឹង ១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ រង្វាន់អ្នកប្រគល់ដីការកោះ ៥០០០៛ សរុប ៧០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់ ៧០០០៛ដែលដើមចោទបានបង់ទុករួចជាស្រេច ។

កាលបើផុតកំណត់ឧទ្ធរណ៍ បង្គាប់ឲ្យឈ្មោះចសធ សងប្រាក់ប្រដាប់ក្តីចំនួន ៧០០០៛ទៅឲ្យដើមចោទវិញ និងបង្គាប់ឲ្យគូក្តីបង់ពន្ធសមាមាត្រចំនួន១%នៃប្រាក់ដែលត្រូវសងទាំងអស់ និងជម្ងឺចិត្តប្រាក់នេះបានដាក់ចូលក្នុងថវិការដ្ឋ៨០% និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០% ។

៩-សាលក្រមនេះជំនុំជំរះ ប្រកាសជាសាធារណៈចំពោះមុខដើមចោទនិងមេធាវីដើមចោទកំបាំងមុខដើមបណ្តឹងតបនិងជាចុងចម្លើយ សម្រេចបើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ គិតចាប់តាំងពីថ្ងៃផុតបណ្តឹងទាស់ ។

បានឃើញបណ្តឹងទាស់លេខ ១១(ញ) ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០១ របស់ឈ្មោះ ឡូទ ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១៤ (ញ) ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចលើសេចក្តីសម្រេចសាលក្រម ។

បានឃើញពាក្យបណ្តឹងទាស់របស់.............. តំណាងឲ្យអ្នកស្រីចសធ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០១ ប្តឹងមិនសុខចិត្តនិងសាលក្រមលេខ ១៤ (ញ) ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០១ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ០៩(ដ) ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តិសម្រេដូចតទៅ ៖

១-ត្រូវបដិសេធចោលសាលក្រមលេខ ១៤ (ញ) ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ទុកជាឥតបានការពេញទាំងមូល ។

២-ទទួលពាក្យបណ្ដឹងចុះថ្ងៃទី២៣ ខែវិច្ឆកា ឆ្នាំ២០០០ របស់ដើមចោទឈ្មោះ ឡូទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៣-ទទួលពាក្យបណ្ដឹងតបចុះថ្ងៃទី ១២ខែវិច្ឆកា ឆ្នាំ២០០០ របស់ចុងចម្លើយឈ្មោះចសធ ជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៤-ទទួលពាក្យបណ្ដឹងបន្ថែមចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០១ របស់មេធាវីឈ្មោះ ប៊ុន ហុន ជាតំណាងឲ្យឈ្មោះចសធ ដែលជាចុងចម្លើយទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែទាស់នឹងគតិច្បាប់ខ្លះៗ ។

៥-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១៥ខែវិច្ឆកា ឆ្នាំ២០០០ រវាងឈ្មោះ គង់ ហេងលី និងមេធាវីឈ្មោះ.............. ចុះថ្ងៃទី០៥ខែកុម្ភៈឆ្នាំ២០០១ ជាមួយអ្នកស្រីចសធ ទុជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

៦-ទទួលស្គាល់ពាក្យសុំទទួលស្គាល់មេធាវីឈ្មោះ.......... និងឈ្មោះ ចុង អៀវហេង ចុះថ្ងៃទី ២០ ខែមេសា ឆ្នាំ២០០១ និងចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០១ ជាមេធាវីការពារក្ដីឲ្យដើមចោទឈ្មោះ ឡូទ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៧-ទទួលស្គាល់កិច្ចសន្យាចុះថ្ងៃទី១៦មិថុនាឆ្នាំ១៩៩៩ របស់គូភាគីទុកជាត្រឹមត្រូវតាមផ្លូវច្បាប់ ។

៨-ទុកសិទ្ធិឲ្យចុងចម្លើយឈ្មោះចសធ ប្ដឹងទាមទារប្រាក់ពិន័យឆ្នាំទី២ និងឆ្នាំទី៣នៃកិច្ចសន្យាចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៩ តាមផ្លូវច្បាប់ ។

៩-បង្គាប់ឲ្យចុងចម្លើយឈ្មោះចសធបង់ប្រាក់ពិន័យចំនួន ៥០០០០ដុល្លា(ប្រាំម៉ឺនដុល្លាអាមេរិក) ទៅឲ្យដើមចោទឈ្មោះឡូទ (តាមប្រការ១២នៃកិច្ចសន្យាចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩) ការសុំលើសពីនេះត្រូវបដិសេធចោល ដោយគិតចាប់តាំងពីសាលក្រមចូលជាស្ថាពរតទៅ ។

១០-បង្គាប់ឲ្យដើមចោទឈ្មោះ ឡូទ សងប្រាក់ថ្លៃពិន័យចំនួន ៥០០០០ដុល្លា ទៅឲ្យចុងចម្លើយឈ្មោះ ចសធ (តាមប្រការ១៣ នៃកិច្ចសន្យាចុះថ្ងៃទី១៦ខែមិថុនាឆ្នាំ១៩៩៩) ការសុំលើសពីនេះត្រូវបដិសេធចោល ដោយគិតចាប់តាំងពីសាលក្រមចូលជាស្ថាពរតទៅ ។

១១-បង្គាប់ឲ្យដើមចោទឈ្មោះឡូទ សងប្រាក់ថ្លៃស្រាបៀរចំនួន ៨០០០កេស ស្មើនឹងទឹកប្រាក់ចំនួន៥៦០០០ដុល្លា និងសងថ្លៃស្រាបៀរដបចំនួន ១៧៥០កេស ស្មើនឹងទឹកប្រាក់ចំនួន ៣០.៦២៥ដុល្លា ទៅឲ្យចុងចម្លើយឈ្មោះចសធការសុំលើសពីនេះត្រូវបដិសេធចោលដោយគិតចាប់តាំងពីសាលក្រមចូលជាស្ថាពរតទៅ ។

១២-រឹបអូសប្រាក់ប្រដាប់ក្ដីគឺពន្ធហ្នឹង និងពន្ធចុះបញ្ជីក្ដីចំនួន ១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន២០០៛ និងរង្វាន់ក្រឡាបញ្ជីប្រគល់ដីកាកោះចំនួន ៥០០០៛ សរុប៧០០០៛ ប្រាក់នេះកាត់យកពីប្រាក់ដែលដើមចោទបានបង់ទុករួចហើយ ។កាលបើហួសបណ្ដឹងឧទ្ធរណ៍ត្រូវបង្គាប់ឈ្មោះឡូទបង់ពន្ធសមាមាត្រ១% នៃប្រាក់ដែលត្រូវសង ប្រាក់នេះត្រូវដាក់ចូលក្នុងថវិការដ្ឋចំនួន៨០% និង

បានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេសចំនួន ២០% ពន្ធសមាមាត្រនេះ ត្រូវឲ្យចុងចម្លើយបង់ទុកជាមុនទើបបង្គាប់ឲ្យដើមចោទសងវិញជាក្រោយ ។

១៣-សាលក្រមនេះជំនុំជំរះជាសាធារណៈ សួរដេញដោលនៅចំពោះមុខគូភាគី និងប្រកាសកំបាំងមុខគូភាគី បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៨ ខែសីហាឆ្នាំ២០០១ របស់ឈ្មោះ.............. ជាមេធាវីតំណាងឲ្យចុងចម្លើយ ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ០៩ (ដ) ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៥ ខែកញ្ញាឆ្នាំ២០០១ របស់ឈ្មោះ ឡូទ ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ០៩(ដ)ចុះថ្ងៃទី២៧ខែកក្កដា ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៨០(ឈ) ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនឹងសេចក្តីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៨ខែសីហា ឆ្នាំ២០០១ របស់លោកមេធាវី.............. ជាមេធាវីតំណាងឲ្យឈ្មោះចសធ ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៥ខែកញ្ញា ឆ្នាំ២០០១ របស់ឈ្មោះឡូទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៣-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ០៩(ដ) ចុះថ្ងៃទី២៧ខែកក្កដា ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញចោលជាអសារបង់ ។

៤-បង្គាប់ឲ្យក្រុមហ៊ុនអ៊ុយ ទៀង ដែលមនាលោកឡូទ ជាតំណាងសងប្រាក់ៈ

ក/ពិន័យថ្លៃស្រាបៀរចំនួន ៦០០០០ដុល្លាអាមេរិក

ខ/ពិន័យឆ្នាំទី១ តាមប្រការទី១៣ នៃកិច្ចសន្យា ចុះថ្ងៃទី១៦ ខែមិថុនាឆ្នាំ១៩៩៩ ចំនួន ៥០០០០ដុល្លាអាមេរិក

គ/ថ្លៃស្រាបៀរខូចគុណភាពដែលបណ្តាលមកពីការហាមឃាត់របស់ដើមចោទ និងប្រាក់បង់ពន្ធ ថ្លៃដឹកជញ្ជូនថ្លៃឈ្នួលឃ្លាំងស្តុកនិងថ្លៃកម្មករ លើកដាក់ចំនួនសរុប៣.២៣៣.៤៥៦ ដុល្លាអាមេរិក

ឃ/ពិន័យឆ្នាំទី២ និងឆ្នាំទី៣ តាមប្រការទី១៣ នៃកិច្ចសន្យាចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៩ ចំនួន៤០០០០០ដុល្លាអាមេរិក (សែសិបម៉ឺនដុល្លាអាមេរិក)

ង/ជម្ងឺចិត្ត និងសោហ៊ុយ ក្នុងការខាតបង់ពេលវេលាចំនួន៥០០០០ដុល្លាអាមេរិកឲ្យទៅចុងចម្លើយ គឺក្រុមហ៊ុនថៃ ហេងចាន់ ដែលមានអ្នកស្រីចសធ ជាតំណាងចាប់ពីពេលដែលសាលដីកានេះចូលជាស្ថាពរ ។ សំណូមពរលើពីនេះ បដិសេធចោល ។

ក្នុងករណីគ្មានប្រាក់សងទេ ត្រូវរឹបអូសទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន អ៊ុយ ទៀង លក់ឡាយឡុងជានាសំណង ។

៥-កាត់យកប្រាក់ប្រដាប់ក្តីដាន់សាលាឧទ្ធរណ៍ចំនួន២៦០០០៛ ដែលចុងចម្លើយបានបង់ទុករួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន ៥១០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៩០០៛ ចំណាយ លើកាកោះចំនួន ១០០០០៛ និងអាជ្ញាធរតុលាការចំនួន ១០០០០៛ ។នៅពេលសាលដីកានេះចូលជាស្ថាពរបង្គាប់ឲ្យដើមចោទ បង់សងទៅចុងចម្លើយវិញ និងបង្គាប់ឲ្យដើមចោទបង់ពន្ធសមាមាត្រ១% លើប្រាក់ត្រូវសងក្នុងចំណុចទី៤ នៃសេចក្តីសម្រេច។

៤-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវីតំណាងឲ្យចុងចម្លើយ កំបាំងមុខដើមចោទ ។

បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ ៧៤ ចុះថ្ងៃទី២៨ខែឧសភា ឆ្នាំ២០០២ របស់លោក.......... មេធាវីតំណាងឲ្យឈ្មោះឡុទប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៨០ (ឈ) ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៤២ (ឈ) ចុះថ្ងៃទី០៥ខែកញ្ញា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០២ របស់លោកមេធាវី .......... ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ ៨០ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

៣-សាលដីកានេះ ជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០២ ចំពោះមុខមេធាវីតំណាងចុងចម្លើយ កំបាំងមុខដើមចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៥ ខែកញ្ញាឆ្នាំ២០០២ កំបាំងមុខមេធាវីតំណាងឲ្យគូក្តី ។បើកផ្លូវប្តឹងសារទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣៤៧ ចុះថ្ងៃទី២០ ខែកញ្ញាឆ្នាំ២០០២ របស់លោក.......... មេធាវីតំណាងឲ្យឈ្មោះឡុទ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៤២(ឈ) ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសារណាការពារ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៣ របស់ឈ្មោះឡុទ ។

បានឃើញសារណាតប ចុះថ្ងៃទី១១ខែកក្កដា ឆ្នាំ២០០៣ របស់ឈ្មោះ ចសធ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថាៈ រឿងនេះជារឿងវិវាទប្តឹងទាមទារប្រាក់និងសុំមោឃភាពកិច្ចសន្យាលក់ ទិញ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យនិងសម្រេច ។

បានស្តាប់ចម្លើយរបស់ឈ្មោះឡុទ នាពេលសវនាការថាៈ ខ្លួនមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ព្រោះទាំងតុលាការថ្នាក់ក្រោមនិងសាលាឧទ្ធរណ៍មិនរកយុត្តិធម៌ឲ្យខ្លួនសោះ ហើយកិច្ច

សន្យាដែលខ្លួនបានធ្វើជាមួយអ្នកស្រីចសធ ត្រឹមត្រូវតែអ្នកស្រីចសធ បែរជាយកស្រាបៀរដែលគ្មានគុណភាពមកឲ្យខ្លួនចែកចាយ ជាហេតុធ្វើឲ្យខ្លួនខាតបង់កិត្តិយស និងទីផ្សារយ៉ាងធ្ងន់ធ្ងរ ហើយស្រាបៀរដែលខូចគុណភាពគឺប្រភេទដប ។ ពេលដែលខ្លួនយកមកលក់ក៏មិនទាន់ដឹងថា ខូចគុណភាពដែរ ស្រាប់តែពេលចែកចាយហើយទើបមានគ្រប់ហាងប្ដឹងមកក្រុមហ៊ុនខ្លួន ។ ចំពោះស្រាបៀរកំប៉ុងបីម៉ឺនកេសតែដឹកបានតែពីរម៉ឺនប្រាំមួយពាន់បួនរយកេស ។ចំពោះស្រាបៀរកំប៉ុងខ្លួនលក់អស់ហើយនៅសល់តែ ៨០០០កេស ដែលខ្លួនមិនទាន់បានសងរហូតដល់សព្វថ្ងៃ ឯស្រាបៀរប្រភេទដបក៏នាំចូលក្នុងឆ្នាំទី១ដែរ គឺក្រុមហ៊ុនអ្នកស្រីនាំចូលហើយដឹកចូលទៅក្នុងឃ្លាំងរបស់អ្នកស្រីតែម្ដង ពេនោះខ្លួនទិញបាន ៥០០កេស ហើយពេលចែកចាយបាន៤ ទៅ១០ ថ្ងៃទើបម្ចាស់ហាងគេយកមកបង្ហាញខ្លួ ធ្វើឲ្យខ្លួនបាត់បង់លុយមិនអាចយកមកវិញបានហើយពេលនោះខ្លួនប្រមូលបានស្រាបៀរ២០កេសមកវិញដែរ ហើយខ្លួនក៏បានធ្វើសំណើទៅអ្នកស្រីចសធ ។ ក្នុងមួយកេស ៧,៥ដុល្លា ហើយបានជាខ្លួនហ៊ានឃាត់ស្រាបៀរអ្នកស្រី ចសធ ពីព្រោះខ្លួនបានបង់ពន្ធចំនួន៣៥០០ដុល្លាដែរ ឯសមត្ថកិច្ចក៏ហាមមិនឲ្យចែកចាយដែរ ហេតុនេះសុំតុលាការជួយរកយុត្តិធម៌ឲ្យខ្លួនផង និងសុំ បដិសេធសាលដីការបស់សាលាឧទ្ធរណ៍ ។

បានស្ដាប់ចម្លើយរបស់ឈ្មោះ ចសធ នាពេលសវនាការថា: គាត់និយាយនេះសុទ្ធតែជាពាក្យបំផ្លើសទាំងអស់ គាត់ថា ស្រាបៀរនេះខូចគុណភាព មកពីគាត់ចង់គេចវេសពីការជំពាក់លុយហើយអ្នកកាន់ កុងត្រូលក៏បានធ្វើការត្រួតពិនិត្យហើយដែរ មិនតែប៉ុណ្ណោះពេលដែលគាត់ប្រាប់ថា ស្រាបៀរនេះខូចគុណភាព ខ្លួនបានដើរទៅស៊ើបសួរតាមតូបចំនួន៣២តូប គ្មានឃើញហាងណាថា ស្រាបៀរនេះខូចគុណភាពទេ គឺដូចគេ ដូចឯង ត្រង់នេះហើយដែលខ្លួនកើតទុក្ខមិនសុខចិត្តទេ។ឆ្នាំទី១គាត់កុំម៉ង់តែ៣០.០០០កេសទេ ហើយកិច្ចសន្យា នេះប្រភេទកំប៉ុង តែក្រោយមកគាត់ឱ្យខ្លួននាំចូលមកជាដបវិញហើយខ្លួន និងគាត់បង់ពន្ធពាក់កណ្ដាលម្នាក់ ។ អ្វីក៏ដោយក្នុងនាមខ្លួនជាឈ្មួញកណ្ដាល ខ្លួនមិនហ៊ាននាំស្រាដែលលោកឡុទ មិនកុំម៉ង់បានទេ ច្បាស់ជា លោកប្ដឹងខ្លួនងាប់ ហើយចាប់ពីថា ស្រាខ្លួនខូចគុណភាពមក គេបានឃាត់ទុករយៈពេល ៧៩ថ្ងៃទើបគេយកទៅ ពិនិត្យ ហើយគេសរសេរថា គ្រាន់តែមិនអាចប្រើប្រាស់ក្នុងទីផ្សារបាន ។

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់លោក .......... ជាមេធាវីការពារឱ្យម្ចាស់បណ្ដឹងសាទុក្ខ នាពេលជំនុំ ជំរះថា: ក្នុងប្រការទី៣នៃកិច្ចសន្យានេះ អ្នកស្រីត្រូវផ្ដល់ឱ្យបានគ្រប់ចំនួនទើបបាន តែអ្នកស្រីផ្ដល់បានតែ ២៦៤០០កេសទេ ដូចនេះខ្វះមិនទាន់បានគ្រប់ចំនួនតាមកិច្ចសន្យាទេ ហេតុនេះអ្នកស្រីមិនបានគោរពកិច្ចសន្យាទេ ហើយការនាំចូលស្រាបៀរប្រភេទដបចូលមក កូនក្ដីខ្លួនទើបតែលក់បាន ៥០០កេស ក៏មានបញ្ហាកើតឡើងគឺមាន ដែលផ្ទុះចេញពីភ្ញៀវ ហើយកូនក្ដីខ្លួនប្រមូលមកវិញបានតែ ២០កេសទេ ពេលខ្លួនយកមកពិនិត្យឃើញថា កករមែន បើតាមច្បាប់ឧស្សាហកម្មមិនអាចលើសដីក្រេប៉ុណ្ណឹងទេ ហើយតុលាការថ្នាក់ក្រោម បែរជាយល់ថា លោកឡុទ ឃាត់បានជាខូចគុណភាពនេះមិនត្រឹមត្រូវទេ ព្រោះតុលាការជាអ្នកឃាត់មិនមែនកូនក្ដីខ្លួន ជាអ្នកឃាត់ទេ ហើយបើសិនខ្លួនជាភ្ញៀវគេ

បានយកស្រាបៀរកករ យកមកឱ្យផឹកនោះខ្លួនមានសិទ្ធិប្ដឹង អ្នកណា ក៏មានសិទ្ធិប្ដឹងដែរ ។ ការនៅតុលាការថ្នាក់ក្រោមលោក អ៊ុន ប៊ុណ្ណាមិនបានហៅខ្លួនទេ ឯនៅសាលាឧទ្ធរណ៍ក៏ ដូច្នោះដែរ ហើយមិនអោយកូនក្ដីខ្លួនប្ដឹងទាស់ទេ និង នៅក្នុងសាលក្រមនេះ មិនឃើញដាក់ថា ប្រកាសជា សាធារណៈទេ ។ សាលាឧទ្ធរណ៍កាត់ក្ដីអយុត្តិធម៌ណាស់ ព្រោះគាត់កាត់តាំងពីម៉ោង ៧h ៣0mn ខ្លួនទៅ មិនទាន់ផង គាត់កាត់តែក្នុងរយៈពេល ២០នាទីតែប៉ុណ្ណោះ ដែលមានសំណុំរឿងនេះក្រាស់បំផុត ។

***សំណូមពរៈ*** សុំបដិសេធសាលដីកាសាលាឧទ្ធរណ៍ និង ស៊ីបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍ ដើម្បី រកយុត្តិធម៌ជាថ្មី និងធ្វើឱ្យចំនីតិវិធី ។ កុំបំផ្លើសនីតិវិធី កុំសម្រេចសេចក្ដីបញ្ច្រាសឯកសារ កុំបំពានឯកសារនៃ គូភាគី ។

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់លោក .............. ជាមេធាវីការពារឱ្យចុងបណ្ដឹងសាទុក្ខនាពេលជំនុំជំរះថាៈ

- កិច្ចសន្យានៅថ្ងៃទី១៦-៦-៩៩ នៅក្នុងកិច្ចសន្យាបានចែងច្បាស់ណាស់ថា នៅក្នុងប្រការទី៣ ក្នុង ការទិញ-លក់នេះ ក្នុងកិច្ចសន្យានេះគេសរសេរថាCIFអ្នកពាណិជ្ជករត្រូវតែយល់នូវពាក្យនេះច្បាស់ណាស់ ។

- ភាគីទាំងពីរ ក្នុងប្រការ៤ គេក៏សរសេរយ៉ាងច្បាស់ដែរ ពេលទៅទិញគាត់អត់បង់លុយត្រង់នេះគាត់ រំលោភមុនគេ និងបានកំណត់ពេលវេលាច្បាស់លាស់ ។

- នៅក្នុងប្រការ១៣ គាត់ត្រូវបង់ប្រាក់ពិន័យ ៤០.០០០ដុល្លា ។ នៅក្នុងសវនាការថ្នាក់ក្រោមគេបាន កាត់កំបាំងមុខគាត់ មកពីគាត់អត់មក ពេលក្រោយគាត់អត់ចូលទៀត គេក៏កាត់តែម្ដងទៅ បើសិនជាពេលកាត់ម្ដង ភាគីខាងនោះមក ខាងនោះអត់ ចុះឡើងនោះតើនីតិវិធីកាត់ដូចម្ដេច មិននៅតែរង់ចាំរហូតហើយឬ ? បើគាត់មិនទិញស្រាបៀរបដហេតុអ្វីក៏ទិញយកអស់ ហើយកុំម៉ង់ជបម្ដងទៀត ។ ពេលមានទំនាស់កូនក្ដីខ្លួនអត់បានដឹងថា គេប្ដឹងគាត់ហើយទេ នៅក្នុងរឿងនេះ បានជាកូនក្ដីខ្លួនឱ្យភាគីម្ខាងទៀតបង់លុយពន្ធ ព្រោះគាត់ បានជំពាក់កូនក្ដីខ្លួនច្រើនពេកគាត់ថាស្រាបៀរនៅសល់២០កេសដែលខូចតែពេលខ្លួនសុំមើលគាត់មិនបង្ហាញទេ។ ពេលកូនក្ដីខ្លួនឱ្យគាត់ប្រមូលមកវិញ គាត់ថាអត់មានហើយគាត់បែរជាឱ្យកូនក្ដីខ្លួនទៅប្ដឹងនៅស្រុកចិនទៅវិញ ដោយថា ស្រានេះខូចគុណភាព ពីនោះមកត្រង់នេះ គាត់ចង់គេចវេសពីការសងលុយឱ្យកូនក្ដីខ្លួន ឯចំណែក ខាងប៉ាស្ទ័រក៏បានបញ្ជាក់ច្បាស់ថាមិនប៉ះពាល់ដល់សុខភាពទេ គេគ្រាន់តែសរសេរថាៈ"ហាមចែកចាយតែប៉ុណ្ណោះ" មិនតែប៉ុណ្ណោះគាត់ថែមទាំងយកទៅចុះកាសែតធ្វើឱ្យបាត់បង់ក្នុងទីផ្សារទាំងមូល ។ កិច្ចសន្យានេះ ប្រកបដោយ សុពលភាព ដូចនេះការរំលោភកិច្ចសន្យាត្រូវតែប្ដឹង តែបែរជាអ្នករំលោភ ជាអ្នកប្ដឹងទៅវិញនៅក្នុងមាត្រា៥០ ក្រិត្យច្បាប់លេខ ៣៨ បាននិយាយច្បាស់ណាស់ ។

***សំណូមពរៈ*** ស៊ីតំកល់សាលដីការបស់សាលាឧទ្ធរណ៍ ក្នុងករណីគ្មានប្រាក់សងត្រូវរឹបអូសទ្រព្យសម្បត្តិ និងដាក់គុកលើរូបរាង្គកាយ ។

- ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីគូភាគ.

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៤៧ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០២ របស់មេធាវី .......... តំណាងឱ្យឈ្មោះឡេទ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាម មាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលលោក ឡេទ បានលើកឡើងក្នុងសារណាចុះថ្ងៃទី០៧-៧-២០០៣ក៏ដូចក្នុងពាក្យបណ្តឹងចុះថ្ងៃទី៣០-៨-២០០០ និងពាក្យបណ្តឹងចុះថ្ងៃទី២៣-១១-២០០០ ថា អ្នកស្រីចសធ បានរំលោភបំពានប្រការ៣ និង៥ នៃកិច្ចសន្យានោះ គឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថាៈ

+វិញ្ញាបនប័ត្រគុណភាពលេខ000.៦០០ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០០ របស់កាំកុងត្រូល បានបញ្ជាក់ថា ស្រាបៀរអាឡាំងដឺឡុងចំនួន ២៣៨០កេស ដែលបាននាំចូលមកនេះ សមស្របទៅតាមតំរូវការ ទាមទារនៃផលិតផលស្រាបៀរសម្រាប់ការប្រើប្រាស់បាន។

- យល់ឃើញថា ការដែលមេធាវីដើមចោទលើកឡើងថា ស្រាបៀរអាឡាំងដឺឡុងចំនួន ១៨៨០ កេសខូចគុណភាពដោយសំអាងទៅលើវិញ្ញាបនប័ត្រគុណភាពលេខ000៨0៩ ចុះថ្ងៃទី១៦-១២-២០០០ របស់កាំកុងត្រូល និង លិខិតបញ្ជាក់អំពីអនាម័យនៃអាហារ ចុះថ្ងៃទី០៨-១១-២០០០ របស់វិទ្យាស្ថានប៉ាស្ទ័រនោះគឺជាការពុំ ត្រឹមត្រូវឡើយពីព្រោះថាៈ

+ការពិនិត្យវិភាគទាំងនេះ ធ្វើក្រោយវិញ្ញាបនប័ត្របញ្ជាក់គុណភាពលេខ ០០០៦០០ ចុះថ្ងៃទី ១៥-៩-២០០០ របស់កាំកុងត្រូល គឺក្រោយភាគីដើមចោទបានប្តឹងឃាត់ស្រាបៀរចំនួន១៨៨០កេស ក្នុងកន្លែង ដែលពុំមានលក្ខណៈបច្ចេកទេសសមស្របសម្រាប់តម្កល់ស្រាបៀរ ។

+ ភាគីដើមចោទមិនបានអនុវត្តតាមប្រការ៤ នៃកិច្ចសន្យាចុះថ្ងៃទី ១៦-០៦-១៩៩៩ ដោយ មិនបានធ្វើ Bank Guarantee ១០០% នោះទេ ។

- យល់ឃើញថា ការដែលមេធាវីដើមចោទ លើកឡើងជំទាស់នឹងប្រាក់ពិន័យ ឆ្នាំទី២ ទី៣ ដែលសាលាឧទ្ធរណ៍សម្រេច ឱ្យកូនក្តីរបស់ខ្លួនសងទៅចុងចម្លើយ ដោយសំអាងហេតុថា ភាគីទាំងពីរបានប្តឹងផ្តល់គ្នាមក ដល់តុលាការតាំងពីឆ្នាំទីមួយម្ល៉េះ នោះគឺជាការពុំត្រឹមត្រូវឡើយ ព្រោះថាៈ

+ ភាគីដើមចោទ បានប្តឹងទារប្រាក់ពីភាគីចុងចម្លើយ និង ប្រាក់ពិន័យដោយយោងកិច្ចសន្យាទិញ-លក់ស្រាបៀរអាឡាំងដឺឡុង ចុះថ្ងៃទី ១៦-៦-១៩៩៩ ប៉ុន្តែ ភាគីដើមចោទ ពុំបានប្តឹងរំលាយ ឬ ព្យួរកិច្ចសន្យាតាមមាត្រា១៩ នៃក្រិត្យច្បាប់លេខ៣៨ក្រច នោះទេ ដូច្នេះកិច្ចសន្យាចុះថ្ងៃទី១៦-៦-១៩៩៩ នៅតែ មានសុពលភាពគតិយុត្តិដែលជាច្បាប់របស់គូភាគីស្របតាមមាត្រា២២ និង២៩ នៃក្រិត្យច្បាប់លេខ ៣៨ក្រច ។

- យល់ឃើញថា សាលដីកាលេខ ១៤២(ឈ) ចុះថ្ងៃទី០៥-៩-២០០២ របស់សាលាឧទ្ធរណ៍ ដែល បានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទម្រង់ និងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីកំបាំងមុខគូក្តី**

**និងមេធាវី ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ៣៤៧ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០២ របស់លោកមេធាវី .......... តំណាងឱ្យលោកឡុទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែ បដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ១៤២(ឈ)ចុះថ្ងៃទី០៥ខែកញ្ញាឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាកប្រដាប់ក្តីចំនួន ១៩.០០៛ ដែលអ្នកស្រី ចសធ បានបងដូសគឺៈ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០៛ប៉ុន្តែប្រាក់នេះត្រូវកាន្ទួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ហើយតម្រូវឱ្យលោកឡោ ទៀង សងប្រាក់ចំនួន ១៩.០០០៛នេះ ទៅឱ្យអ្នកស្រីចសធវិញ ។

៤-សាលដីកានេះជំនុំជំរះនៅថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០០៣ និង ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ២៣ ខែតុលា ឆ្នាំ២០០៣ ។